ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤៦/១៧-ម៉េង ជា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ម៉េង ជា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល**

អាសយដ្ឋាន ៖ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៦ ៨៥ ១០ ០៤ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

១- លោក គង់ មិនគង់ នាយករង

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ម៉េង ជា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល**

អាសយដ្ឋាន ៖ ភូមិចោមចៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៦ ៧៣ ៦៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ ៥ ភាគរយ ឱ្យបានម្តង គិតចាប់ពីក្រុមហ៊ុនបើក រហូតដល់ឆ្នាំ២០១៨។ ដោយឡែកភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនពុំអាចផ្តល់ជូនតាមការទាមទារបានទេ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់។

៣- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល លេខ ១០៦២ ក.ប/អក/វក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧។

### សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងជួបប្រជុំមុនសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ ៖** ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៧ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ការិយាល័យវិវាទការងារទី៤ នៃនាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតតាមរយៈទូរសព្ទ ស្តីពីករណីកម្មករនិយោជិតធ្វើកូដកម្ម ទាមទារឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរជូនកម្មករនិយោជិត។ ក្រោយពីបានទទួលបណ្តឹងនេះ នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងាររួមនេះ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧ លើចំណុចវិវាទចំនួន ៣ ចំណុច ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ៣

THE ARBITRATION COUNCIL

ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ីនដាស់ស្ទ្រីល លេខ ១០៦២ កប/អក/វក ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧។ នៅថ្ងៃដដែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ីនដាស់ស្ទ្រីល ចុះនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីសំណើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជាដើម្បីឱ្យកម្មករនិយោជិតដែលធ្វើកូដកម្មឱ្យចូលធ្វើការងារវិញ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០០៤/១៧ កបអ. ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ឱ្យផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ីនដាស់ស្ទ្រីល រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ តទៅ តាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្តីបញ្ជានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា កម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមរយៈលិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៣២៦ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៧ និងលិខិតអញ្ជើញភាគីនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៣២៧ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧។ នៅថ្ងៃកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល មុនដំណើរការនៃកិច្ចប្រជុំចាប់ផ្តើម លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទាក់ទងទៅកាន់តំណាងភាគីកម្មករនិយោជិត ចំនួន ២ នាក់ គឺ កញ្ញា ចិន លីដា និង លោក ស៊ុំ សឿនសាមិន ហើយទទួលបានព័ត៌មានថា កម្មករនិយោជិតភាគច្រើនចូលធ្វើការងារវិញអស់ហើយ នៅសល់តែកម្មករនិយោជិតចំនួនប្រហែលជា ១០០ នាក់ ដែលមិនទាន់ចូលធ្វើការងារវិញ ហើយតំណាងកម្មករនិយោជិតទាំងនោះ ក៏មិនបានចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល តាមការអញ្ជើញនោះទេ។

ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនេះ មានតែតំណាងភាគីនិយោជកប៉ុណ្ណោះ មានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីនិយោជកក៏បានបញ្ជាក់ដែលថា កម្មករនិយោជិតភាគច្រើនចូលធ្វើការងារវិញអស់ហើយ មានតែកម្មករនិយោជិតចំនួនប្រហែលជា ២០០ ឬ ៣០០ នាក់ ដែលធ្វើកូដកម្មនៅឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ របស់នាយកក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល ប្រគល់សិទ្ធិជូនលោក គង់ មិនគង់។

២- លិខិតចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ របស់តំណាងក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលចេញបញ្ជាឱ្យកម្មករនិយោជិតដែលធ្វើកូដកម្មត្រូវចូលធ្វើការងារវិញជាបន្ទាន់។

៣- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៧ របស់នាយកក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល ប្រគល់សិទ្ធិជូនលោក គង់ មិនគង់។

៤- លក្ខន្តិកៈក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល បានតម្កល់ទុក លេខ ១៥៣៧/២០១៥ ពណ.ចបព ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល លេខ MOC-៥០៧៣៥៥២៤ ពណ.ចបព ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

៦- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល លេខ ៤០ កប/អក/អធក ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៣ បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

៧- លិខិតស្នើសុំបំរើការងារ-កិច្ចសន្យាការងារ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ អ៊ុន សំអឿន, លី ដាលីន, ម៉ម សុផល, មូរ អម, ចាន់ យ៉ាត និង គីម ម៉ៅ។

៨- លិខិតស្នើសុំបំរើការងារ-កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ ឃួន រ៉ន។

៩- លិខិតស្នើសុំបំរើការងារ-កិច្ចសន្យាការងារ និងសំបុត្របញ្ជាក់កំណើត របស់ឈ្មោះ កែវ ស្រីមុំ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល លេខ ១០៦២ ក.ប/ អក/វក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល លេខ ០១៦/១៧ កប/អក/វក/លបវ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៤/១៧ កបអ. ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៧។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៣២៦ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៧។

៣- លិខិតអញ្ជើញភាគីនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៣២៧ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា ៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម*"។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលពលកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៩/០៦-សាង វ៉ូ, លេខ ៣៥/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩ &១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាញូ, លេខ ១០៤/១៣-សាប្រីណា (ខេមបូឌា), លេខ ៣២២/១៤-ជីមលី(ខេមបូឌា) គីធីអុី អិលធីឌី, ០៧១/១៥ - អ៊ឹម វើ កាត់ដេរ អន្តរជាតិ សាខាកំពង់ឆ្នាំង និងលេខ ០២១/១៦ - ស្តារឡៃថ៍ អឹកែរិល មេនូហ្វេកធើរីង)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ខណៈពេលដែលសំណុំរឿងវិវាទបញ្ជូនមកដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល កម្មករនិយោជិតកំពុងតែធ្វើកូដកម្ម ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណើពីតំណាងនិយោជកឱ្យចេញសេចក្តី

បញ្ហា។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបញ្ជា លេខ ០០៤/១៧ កបអ. ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ ឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្ម និងចូលធ្វើការធម្មតា និងបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីសួរបញ្ជាក់ពីករណីកូដកម្មនេះ។ ដោយឡែក ភាគីកម្មករនិយោជិតមិនបានចូលរួមកិច្ចប្រជុំនេះទេ ហើយបានផ្តល់ព័ត៌មានតាមរយៈទូរសព្ទមុនកិច្ចប្រជុំសវនាការអាជ្ញាកណ្តាលថា កម្មករនិយោជិតចំនួនប្រហែលជា ១០០ នាក់ នៅតែធ្វើកូដកម្មដដែល ដែលនេះក៏ស្របតាមអំណះអំណាងរបស់ភាគីនិយោជកក្នុងកិច្ចប្រជុំមុនសវនាការផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កូដកម្មនៅតែបន្តធ្វើ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចបន្តនីតិវិធី និងដំណើរការសវនាការបានទេ។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៤៦/១៧-ម៉េង ដា ហ្វូតវៀ អ៊ិនដាស់ស្ទ្រីល។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ៖ **ឈឹម តិរម្យ**

ហត្ថលេខា៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ៖ **អាន ទីរៈ**

ហត្ថលេខា៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា៖ ------------------------------